# សេចក្តីសប្បុរសពុំប្រាត់បង់ទៅឡើយ

*ដោយ  សិលវៀ អេច អ័លរ៉េដ*
*ជាទីប្រឹក្សាទីមួយនៅក្នុង គណៈប្រធានសមាគមន៍សង្គ្រោះទូទៅ*

ថ្មីៗនេះស្វាមីរបស់ខ្ញុំ និងខ្ញុំបានទស្សនាទីក្រុង ណៅវូ អិលលីណោយ។ ខណៈដែលយើងអង្គុយក្នុងបន្ទប់ជាន់លើ នៃឃ្លាំងស្តុកឥដ្ឋក្រហម ជាកន្លែងដែលព្យាការី យ៉ូសែប ស៊្មីធ  បានប្រើធ្វើជាការិយាល័យ និងធ្វើកិច្ចការផ្សេងៗនៅទីនោះ។ យើងបានស្តាប់អ្នកនាំភ្ញៀវម្នាក់ដោយយកចិត្តទុក្ខដាក់ ដែលរៀបរាប់ប្រាប់យើង អំពីព្រឹត្តិការណ៍ប្រវត្តិសាស្រ្ត នៃការស្តារឡើងវិញដែលបានកើតឡើងនៅទីនោះ។

ខ្ញុំបានគិតអំពីការបង្កើតសមាគមសង្គ្រោះ និងការបង្រៀនមួយចំនួន ដែលបងប្អូន ស្រ្តីនៃ សមាគមសង្គ្រោះបានទទួលពីព្យាការី យ៉ូសែប  នៅបន្ទប់នោះ។ ការបង្រៀន ទាំងនោះក្លាយជាគោលការណ៍គ្រឹះ ដែលបងប្អូនស្រ្តីនៃសមាគមសង្គ្រោះ បានសាង សង់នៅលើ។ គោលបំណងនៃការបង្កើនសេចក្តីជំនឿ ការពង្រឹងគេហដ្ឋាននៃស៊ីយ៉ូន និងការស្វែងរក និងការជួយអស់អ្នកដែលត្រូវការជំនួយ គឺបានស្ថាបនាតាំងពីដំបូង។ គោលការណ៍ទាំងនោះគឺនៅបន្តជាការព្យាករដ៏មានអទិភាពដែលមិនផ្លាស់ប្តូរឡើយ។

នៅក្នុងការប្រជុំមួយនៅសម័យនោះ ព្យាការី យ៉ូសែប  បានដកស្រង់ចេញពីការសរសេរ របស់ព្យាការី ប៉ុល ទៅកាន់ប្រជាជន កូរិនថូស។ នៅក្នុងការពិភាក្សាដ៏មានព្រះចេស្តា អំពីសប្បុរសធម៌របស់គាត់ ប៉ុលបានយោងទៅនឹង សេចក្តីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីសប្បុរស បញ្ចប់ជាមួយ « ប៉ុន្តែសេចក្តីដែលវិសេសជាងគេគឺសេចក្តីស្រឡាញ់ » ។ [1]

គាត់បានពិពណ៌នាលក្ខណៈសម្បត្តិមួយចំនួននៅក្នុងសេចក្តីសប្បុរស។ គាត់បាន និយាយថា៖  « ឯសេចក្តីស្រឡាញ់ តែងតែអត់ធ្មត់ ហើយក៏សប្បុរស សេចក្តីស្រឡាញ់មិនចេះ ឈ្នានីស មិនចេះអួតខ្លួន ក៏មិនដែលមានចិត្តធំផង។ ...មិនដែលរកប្រយោជន៍ផ្ទាល់ខ្លួន មិនរហ័សខឹង មិនប្រកាន់ទោស  មិនដែលអរសប្បាយចំពោះសេចក្តីទុច្ចរិតឡើយ គឺអរសប្បាយតែនឹងសេចក្តីស្មោះ ត្រង់វិញ ក៏គ្របបាំងទាំងអស់ ជឿទាំងអស់ សង្ឃឹមទាំងអស់ ហើយទ្រាំទ្ររឿងទាំងអស់។ សេចក្តីសប្បុរសពុំបាត់បង់ទៅឡើយ »។ [2]

ក្នុងការមានប្រសាសន៍ទៅកាន់បងប្អូនស្រីទាំងឡាយ ព្យាការី  យ៉ូសែប  បានមានប្រសាសន៍ថា៖  « អ្នកមិនត្រូវកំណតទស្សនៈរបស់អ្នកដោយគិតអំពីគុណធម៌នៃអ្នកជិតខាងរបស់អ្នកឡើយ ...អ្នកត្រូវពង្រីកព្រលឹងរបស់អ្នកឆ្ពោះ ទៅរកអ្នកដទៃបើសិនជាអ្នក [នឹង] ធ្វើដូចព្រះយេស៊ូវ... នៅពេលអ្នកបង្កើនសេចក្តីសុចរិត និងគុណធម៌ ខណៈដែលអ្នកបង្កើនសេចក្តីល្អ --- ចូរឲ្យ ដួងចិត្តរបស់អ្នកបើកទូលាយទៅកាន់អ្នកដទៃ --- អ្នកត្រូវមានចិត្តអត់ធ្មត់ដ៏យូរ ហើយរែកពន់កំហុស និងភាពខុសឆ្គងនៃមនុស្សជាតិ ។ ឱ ព្រលឹងនៃមនុស្សមានតម្លៃយ៉ាងណា! »[3]

ព្រះគម្ពីបានប្រកាសថា៖ « សេចក្តីសប្បុរសពុំបាត់បង់ទៅឡើយ » បានក្លាយទៅជាបាវចនា របស់សមាគមសង្គ្រោះ ព្រោះវាបានឱបក្រសោបការបង្រៀនទាំងនេះ និងការទទួលខុសត្រូវដែលព្យាការី យ៉ូសែប ស៊្មីធ បានប្រគល់ឲ្យបងប្អូនស្រ្តីឲ្យ « សម្រាលទុក្ខអ្នកក្រ » និង « សង្គ្រោះព្រលឹងទាំងឡាយ » ។ [4]

គោលការណ៍គ្រឹះទាំងនេះ ត្រូវបានឱបក្រសោបដោយបងប្អូនសមាគមសង្គ្រោះ នៅទូទាំងពិភពលោក ត្បិតនេះគឺជាចរិតនៃកិច្ចការសមាគមសង្គ្រោះ ។ តើអ្វីជាសេចក្តីសប្បុរស? តើយើងអាចទទួលបានសេចក្តីសប្បុរសដោយរបៀបណា?

ព្យាការី មរ៉ូណៃ បានឲ្យនិយមន័យពាក្យ សេចក្តីសប្បុរសថាជាសេចក្តីស្រឡាញ់ដ៏សុទ្ធសាធនៃព្រះគ្រីស្ទ [5] ខណៈ ដែលប៉ុល បង្រៀនថា៖ « សេចក្តីស្រឡាញ់...ជាចំណងនៃសេចក្តីគ្រប់លក្ខណ៍ »[6] ហើយនីហ្វៃ បានរំលឹកដល់យើងថា៖ « ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់បានប្រទានបញ្ញត្តិមួយថា មនុស្សលោកទាំងអស់ត្រូវមានសេចក្តីសប្បុរស ឯសេចក្តីសប្បុរសនោះ គឺជាសេចក្តីស្រឡាញ់ »។ [7] ដើម្បីរំឭកដល់ការពិពណ៌នារបស់ប៉ុល កាលពីមុនអំពីសេចក្តីសប្បុរស យើងបានរៀនថា សេចក្តីសប្បុរសគឺមិនមែនជាសកម្មភាពតែមួយ ឬរបស់ម្យ៉ាងដែលយើងឲ្យទៅនោះទេ ប៉ុន្តែជាចរិតលក្ខណៈ ជាសណ្ឋានចិត្ត ជាអារម្មណ៍ចិត្តល្អ ជាអារម្មណ៍ដែលបង្កើតឲ្យមាននូវ សកម្មភាពនៃសេចក្តីស្រឡាញ់។

មរមន ក៏បានបង្រៀនផងដែរថា សេចក្តីសប្បុរស មាននៅជាមួយនឹងពួកសិស្សដ៏ពិតនៃព្រះអម្ចាស់ ហើយថាសេចក្តីសប្បុរស ធ្វើឲ្យអ្នកដែលមានវាបានបរិសុទ្ធ។ [8] បន្ថែមពីលើនេះទៀត យើងបានរៀនថា សេចក្តីសប្បុរសជាអំណោយដ៏ទេវភាពដែលយើងត្រូវតែស្វែងរក និងអធិស្ឋានសូម។ យើងត្រូវតែមានសេចក្តីសប្បុរសនៅក្នុង ដួងចិត្តរបស់យើង ដើម្បីយើងអាចគ្រងនគរសេឡេស្ទាល។ [9]

ជាមួយនឹងការយល់ដឹងថា ព្រះអម្ចាស់ស្នើសុំឲ្យយើង « ចូរបំពាក់ខ្លួន [របស់អ្នក]ជាមួយចំណងនៃសេចក្តីសប្បុរស » [10] យើងត្រូវសួរថាតើលក្ខណៈសម្បត្តិមួយណាដែលនឹងជួយយើងអភិវឌ្ឍន៍សេចក្តីសប្បុរស។

ដំបូងយើងត្រូវមានបំណងប្រាថ្នាបង្កើននូវសេចក្តីសប្បុរស និងប្រែក្លាយឲ្យកាន់តែដូចព្រះគ្រីស្ទ។

ជំហានបន្ទាប់គឺអធិស្ថាន ។ មរមន បានដាស់តឿនយើងឲ្យ៖  « ចូរអធិស្ឋានដល់ព្រះវរបិតា ដោយអស់ពីកម្លាំងចិត្ត ដើម្បី [យើង ] រាល់គ្នា បានពោរពេញដោយសេចក្តីស្រឡាញ់ » ។ សេចក្តីស្រឡាញ់នៃព្រះ គឺជាសេចក្តីសប្បុរស ហើយនៅពេលយើងបំពេញតាមសេចក្តីស្រឡាញ់ទាំងនេះ  នោះ «  យើងរាល់គ្នានឹងបានដូចជាទ្រង់ » ។ [11]

ការអានព្រះគម្ពីររាល់ថ្ងៃ អាចធ្វើឲ្យគំនិតរបស់យើងឆ្ពោះទៅរកព្រះអង្គសង្គ្រោះ និងមានបំណងប្រាថ្នាកាន់តែប្រែក្លាយដូចទ្រង់។

ក្នុងការិយាល័យរបស់ខ្ញុំ ខ្ញុំជ្រើសរើសព្យួររូបគំនូរដែលគូរដោយ មីណឺវ៉ា ទីឆឺត ដែលមានចំណងជើងថា *សង្គ្រោះចៀមដែលវង្វេងផ្លូវ* ។ វាបានពិពណ៌នាអំពីព្រះអង្គសង្គ្រោះឈរក្នុងចំណោមហ្វូង ចៀមរបស់ទ្រង់ និងបីកូនចៀមតូចមួយយ៉ាងទន់ភ្លន់នៅក្នុងព្រះហស្តទ្រង់។ វាបានជួយដល់ខ្ញុំឆ្លុះបញ្ចាំងពីព្រះបន្ទូលអង្វររបស់ទ្រង់ថា៖ «  ចូរឲ្យចំណីដល់ហ្វូងចៀមខ្ញុំស៊ីផង »[12] ដែលចំពោះខ្ញុំគឺមានន័យថា ចូរប្រកាសផ្សាយដល់អស់អ្នកដែលនៅជុំវិញអ្នក ហើយយកចិត្តទុកដាក់ដល់អស់អ្នកណាដែលស្ថិតក្នុងសេចក្តីត្រូវការពិសេស។

ព្រះអង្គសង្គ្រោះគឺជាគំរូដ៏ឥតខ្ចោះអំពីការពង្រីកសេចក្តីសប្បុរស។ នៅក្នុងអំឡុងពេលនៃការបំរើរបស់ទ្រង់នៅក្នុងជីវិតរមែងស្លាប់ ទ្រង់បានបង្ហាញសេចក្តីមេត្តាករុណា ដល់អស់អ្នកដែលអត់ឃ្លាន ដល់មនុស្សមានបាប ដល់មនុស្សតូចតាច និងដល់មនុស្សឈឺ។ ទ្រង់បានបំរើមនុស្សទ័លក្រ និងពួកអ្នកមាន ដល់ស្ត្រី ដល់កុមារ និងបុរស ដល់ក្រុមគ្រួសាររបស់ទ្រង់ មិត្តភិក្ត និងមនុស្សចម្លែក។ ទ្រង់បានអភ័យទោសដល់មនុស្សចោទប្រកាន់ទ្រង់ ទ្រង់រងទុក្ខ និងសុគតដើម្បីមនុស្សជាតិទាំងមូល។

នៅក្នុងជីវិតរបស់លោក ព្យាការី យ៉ូសែប ស៊្មីធ ក៏បានអនុវត្តន៍សេចក្តីសប្បុរស នៅពេលដែលលោកបានពង្រីកនូវសេចក្តីស្រឡាញ់ក្នុងនាមជាបងប្អូនប្រុស និងការគោរពចំពោះអ្នកដទៃ។ លោកត្រូវបានគេទទួលស្គាល់ចំពោះ ចិត្តល្អ ការអត់ឱន សេចក្តីមេត្តា និងយកចត្តិទុកដាក់របស់លោកចំពោះអ្នកដែលនៅជុំវិញលោក។

បច្ចុប្បន្ននេះ  យើងមានពរដោយមានព្យាការីដែលបានធ្វើជាគំរូនៃសេចក្តីសប្បុរស។ ប្រធាន ថូម៉ាស អេស ម៉នសុន គឺជាគំរូសំរាប់យើង និងពិភពលោកទាំងមូល។ លោកបានបំពាក់ចំណងនៃសេចក្តីសប្បុរស ។ លោកមានចិត្តល្អ មានសេចក្តីមេត្តា និងចិត្តអាណិតអាសូរ ដែលជាអ្នកបំរើយ៉ាងពិតប្រាកដរបស់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ។

ប្រធាន ម៉នសុន បានបង្រៀនថា៖ «  សេចក្តីសប្បុរសគឺការមានចិត្តអំណត់ជាមួយអស់អ្នកណាដែលមើលស្រាលយើង។ វាតទល់ប្រឆាំងនិងការអាក់អន់ចិត្តបានដោយងាយ។ វាគឺជាការព្រមទទួលយកភាពទន់ខ្សោយ និងកំហុស។ វាគឺជាការព្រមទទួលស្គាល់នូវលក្ខណៈពិតរបស់បុគ្គលណាមួយ។ គឺមិនសំដៅលើរូបរាងខាងក្រៅជំនួសឲ្យចរិតលក្ខណៈ ដែលមើលមិនឃើញក្នុងពេលនោះ។ វាគឺជាការទប់ទល់ការមានបំណងក្នុងការកាត់សេចក្តីអ្នកដទៃ» ។ [13]

ពេលដែលយើងមានសេចក្តីសប្បុរស គឺយើងមានឆន្ទៈបំរើ និងជួយអ្នកដទៃ ទោះជាក្នុងពេលដែលសមហេតុផល និងទោះជាមិនគិតថាគេនឹងទទួលស្គាល់ ឬមានបានតបស្នងវិញក៏ដោយ។ យើងមិនរង់ចាំឲ្យមានការចាត់តាំងដើម្បីជួយទេ ពីព្រោះវាជាចរិតពីធម្មជាតិរបស់យើង។ ពេលយើងជ្រើសរើសមានចិត្តល្អ ខ្វល់ខ្វាយ មានចិត្តអាណិតអាសូរ អត់ធ្មត់ ព្រមទទួលយក អភ័យទោស ចុះសម្រុងជាមួយអ្នកដទៃ និងមិនអាត្មានិយម នោះយើងរកឃើញថាខ្លួនយើងហ៊ុមព័ទ្ធដោយសេចក្តីសប្បុរស។

សមាគមសង្គ្រោះបានផ្តល់នូវការបម្រើតាមរបៀបជាច្រើនរាប់មិនអស់ ។ វិធីមួយដ៏សំខាន់ ជាងគេក្នុងចំណោមវិធីទាំងឡាយនៃការអនុវត្តន៍សេចក្តីសប្បុរស គឺតាមរយៈការបង្រៀនសួរសុខទុក្ខ។ តាមរយៈការបង្រៀនសុខទុក្ខដ៏មានប្រសិទ្ធភាព យើងមានឱកាសជាច្រើនដើម្បីស្រឡាញ់ បង្រៀន និងបំរើអ្នកដទៃ។ ការសម្តែងនូវសេចក្តីសប្បុរស ឬសេចក្តីស្រឡាញ់ នោះវាញែក និងបន្សុតព្រលឹងរបស់យើងឲ្យបានបរិសុទ្ធ ហើយវានឹងជួយយើងឲ្យកាន់តែប្រែក្លាយដូចព្រះអង្គសង្គ្រោះ។

វាជាការអស្ចារ្យណាស់ ខណៈដែលខ្ញុំបានធ្វើជាសាក្សី ចំពោះសកម្មភាពសប្បុរស ដ៏ច្រើនសន្ធឹកសន្ធាប់ដែលបានធ្វើឡើងប្រចាំថ្ងៃ ពីសំណាក់គ្រូបង្រៀនសួរសុខទុក្ខនៅជុំវិញពិភពលោកដែលបានធ្វើការបំរើដល់សេចក្តីត្រូវការចំពោះបងប្អូនស្ត្រីម្នាក់ៗ និងក្រុមគ្រួសារ ដោយមិនគិតពីខ្លួនឯង។ ខ្ញុំសូមនិយាយទៅកាន់គ្រូបង្រៀនសួរសុខទុក្ខដ៏ស្មោះត្រង់ទាំងនេះ ថា តាមរយៈសកម្មភាពនៃសេចក្តីសប្បុរសតូចៗទាំងនេះ គឺអ្នកបានធ្វើតាមព្រះអង្គសង្គ្រោះ ហើយអ្នកបានធ្វើជាឧបករណ៍នៅក្នុងព្រះហស្តរបស់ ទ្រង់ នៅពេលដែលអ្នកជួយ យកចិត្តទុកដាក់ លើកស្ទួយ លួងលោម ស្តាប់ លើកទឹកចិត្ត បីបាច់ បង្រៀន និងពង្រឹងបងប្អូនស្ត្រី នៅក្រោមការយកចិត្តទុក្ខដាក់របស់អ្នក។ ខ្ញុំសូមចែកចាយគំរូដោយសង្ខេប ពីការបំរើដូច្នេះ។

រ៉ូស្សា រងទុក្ខដោយសារជម្ងឺទឹកនោមផ្អែម និងជម្ងឺផ្សេងៗទៀត ។ នាងបានចូលរួមក្នុងសាសនាចក្រកាលពី ពីរបីឆ្នាំមុន។ នាងជាម្តាយមេម៉ាយនៃកូនប្រុសវ័យជំទង់ម្នាក់។ ជាញឹកញាប់នាងត្រូវសំរាកនៅមន្ទីរពេទ្យម្តងពីរបីថ្ងៃ។ គ្រូបង្រៀនសួរសុខទុក្ខរបស់នាងមិនត្រឹមតែនាំនាងទៅមន្ទីរពេទ្យប៉ុណ្ណោះទេ ពួកគេថែមទាំងបានសួរសុខទុក្ខ និងលើកទឹកចិត្តនាងនៅមន្ទីរពេទ្យ ព្រមទាំងជួយមើលកូនប្រុសរបស់នាងទាំង នៅផ្ទះ និងនៅសាលា។ គ្រូបង្រៀនសួរសុខទុក្ខរបស់នាងបានបំរើដូចជាមិត្តភក្តិ និងជាក្រុមគ្រួសាររបស់នាងអញ្ចឹង។

បន្ទាប់ពីការជួបសួរសុខទុក្ខបងស្រី ពិសេសម្នាក់នេះ ខេធី បានដឹងថា បងស្រីម្នាក់នេះមិនចេះអានទេ ប៉ុន្តែគាត់ចង់ចេះ។ ខេធី បានស្ម័គ្រចិត្តជួយគាត់ ទោះបីជានាងដឹងថា វាត្រូវ ចំណាយពេល មានការអត់ធ្មត់ និងស៊ូទ្រាំក៏ដោយ។

អេមីលី គឺជាភរិយាវ័យក្មេងមួយរូប ដែលកំពុងស្វែងរកសេចក្តីពិត។ ស្វាមីរបស់នាង មីកែល មិនសូវជាចាប់អារម្មណ៍ក្នុងរឿងសាសនាប៉ុន្មានទេ។ នៅពេលដែល អេមីលី ធ្លាក់ខ្លួនឈឺ ហើយត្រូវចំណាយពេលខ្លះនៅក្នុងមន្ទីរពេទ្យនោះ ខាលី ជាស្ត្រីនៃសមាគមសង្គ្រោះ ហើយក៏ត្រូវជាអ្នកជិតខាងរបស់នាងផង បានយកអាហារសំរាប់ក្រុមគ្រួសារ របស់នាង ថែទាំទារករបស់នាង សំអាតផ្ទះ និងបានរៀបចំឲ្យ អេមីលី ទទួលនូវការប្រសិទ្ធិពរពីបព្វជិតភាពទៀត។ សកម្មភាពសប្បុរសធម៌នេះបានបន្ទន់ ដួងចិត្តរបស់ មីកែល។ គាត់បានសម្រេចចិត្តចូលរួមក្នុងការប្រជុំសាសនាចក្រ ហើយជួបជាមួយពួកអ្នកផ្សព្វផ្សាយសាសនា។ អេមីលី និង មីកែល ទើបបានទទួលបុណ្យជ្រមុជ ទឹកក្នុងពេលថ្មីៗនេះ។

សេចក្តីសប្បុរសពុំបាត់បង់ទៅឡើយ។ សេចក្តីសប្បុរស គឺចិត្តល្អ មិនស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន គ្របបាំងទាំងអស់ ហើយទ្រាំទ្រទាំងអស់។

ប្រធាន ហិនរី ប៊ី អាវរិង បានមានប្រសាសន៍ថា៖ « ប្រវត្តិសាស្ត្រនៃសមាគមសង្គ្រោះ គឺពោរពេញទៅដោយដំណើររឿងដ៏អស្ចារ្យនៃការបំរើដ៏ឥតសម្ញៃ… សមាគមនេះគឺត្រូវបានបង្កើតឡើងដោយ ស្ត្រីដែលមានដួងចិត្តដ៏សប្បុរសគឺផុស ចេញពីការផ្លាស់ប្តូរដួងចិត្ត តាមរយៈលក្ខណៈសម្បត្តិ និងតាមរយៈការគោរពបទបញ្ញត្តិ ដែលបានផ្តល់ឲ្យតក្នុងសាសនាចក្រពិតរបស់ព្រះអម្ចាស់ តែមួយប៉ុណ្ណោះ។ អារម្មណ៍នៃសេចក្តីសប្បុរសរបស់ពួកគេបានមកពីទ្រង់ តាមរយៈដង្វាយធួនរបស់ទ្រង់។ សកម្មភាពនៃសេចក្តីសប្បុរសរបស់ពួកគេ គឺបានដឹកនាំតាមរយៈគំរូរបស់ទ្រង់--- ហើយផុសចេញមកក្រៅតាមរយៈអំណរគុណសំរាប់អំណោយនៃសេចក្តីករុណាដ៏គ្មានទីបំផុត --- និងតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ដែលទ្រង់បានបញ្ជូនមកដើម្បីនៅជាប់ជាមួយអ្នកបំរើរបស់ទ្រង់ នៅក្នុងបេសកកម្ម នៃសេចក្តីមេត្តាករុណារបស់ពួកលោក។ ដូច្នេះហើយ ទើបពួកគេបានធ្វើ ការណ៍មិនធម្មតា សំរាប់អ្នកដទៃ និងស្វែងរកសេចក្តីអំណរ សូមម្បីតែនៅក្នុងពេលដែលពួកលោកមិនអាច បំពេញសេចក្តីត្រូវការផ្ទាល់ខ្លួនដ៏ធំធេងក្តី » ។ [14]

ការផ្តល់នូវការបំរើ និងពង្រីកសេចក្តីសប្បុរសឆ្ពោះទៅរកអ្នកដទៃ ជួយយើងយក ឈ្នះលើ ការលំបាកផ្ទាល់ខ្លួនរបស់យើង ហើយធ្វើឲ្យវាមើលឃើញហាក់បីដូចជា មិនសូវមានឧបសគ្គ។

ឥឡូវនេះខ្ញុំសូមដកទៅរកការបង្រៀនរបស់ព្យាការី យ៉ូសែប ទៅកាន់បងប្អូនស្ត្រីកាលពីជំនាន់មុននៃការស្តារឡើងវិញ។លោកជំរុញឲ្យរួសរាន់ក្នុងការអនុវត្តន៍ សេចក្តីសប្បុរស និងសេចក្តីមេត្តា លោកមានប្រសាសន៍ថា៖ « ប្រសិនបើអ្នករស់នៅតាមគោលការណ៍ទាំងនេះ អ្នកនឹងមានរង្វាន់ដ៏មហិមា និងដ៏រុងរឿង នៅក្នុង នគរសេឡេស្ទាល! ប្រសិនបើអ្នករស់នៅតាមអភ័យឯកសិទ្ធរបស់អ្នក នោះទេវតាទាំង ឡាយមិនអាចបញ្ឈប់ទាក់ទងជាមួយអ្នកឡើយ »។ [15]

ដូចជាកាលពីសម័យមុននៅក្នុងទីក្រុង ណៅវូ ជាកន្លែងដែលបងប្អូនស្ត្រីទាំងឡាយបានចេញទៅជួយអស់អ្នកដែលស្ថិតក្នុងសេចក្ដីត្រូវការដូចជាបច្ចុប្បន្ននេះដែរ។ បងប្អូនស្ត្រីនៅក្នុងនរគនេះគឺជាសរសរទ្រូងយ៉ាងអស្ចារ្យនៃភាពរឹងមាំខាងវិញ្ញាណ ការបំរើដោយក្ដីមេត្តា និងការលះបង់។ គ្រូបង្រៀនសួរសុខទុក្ខដែលប្រកបដោយការលះបង់ទាំងនេះ សួរសុខទុក្ខ និងយកចិត្តទុកដាក់ចំពោះគ្នាទៅវិញទៅមក។ ពួកគេបានធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ និងធ្វើតាមអ្វីដែលទ្រង់ធ្វើ។

ស្ត្រីទាំងអស់នៅក្នុងសមាគមសង្គ្រោះអាចទទួលបាននូវសេចក្ដីស្រឡាញ់ ដោយការដឹងថាសកកម្មភាពតូចតាចនៃសេចក្ដីសប្បុរសរបស់ពួកគេ មាននូវអំណាចនៃការព្យាបាលសំរាប់អ្នកដទៃ និងខ្លួនឯង។ ពួកគេដឹងយ៉ាងពិតប្រាកដថា សេចក្ដីសប្បុរសគឺជាសេចក្ដីស្រឡាញ់ដ៏ សុទ្ធសាធនៃព្រះគ្រីស្ទ និងមិនដែលផុតឡើយ។

ពេលដែលអ្នកអានអំពីប្រវត្តិសាស្ត្ររបស់សមាគមសង្គ្រោះ វានឹងជួយបំផុសគំនិត អ្នកឲ្យដឹងថា គោលការណ៍នៃដំណឹងល្អ គឺជាបាវចនាក្នុងសៀវភៅទាំងមូល។

ខ្ញុំសូមបញ្ចប់ជាមួយនឹងការអញ្ជើញដល់ស្ត្រីទាំងអស់ក្នុងសាសនាចក្រ ឲ្យទូលសុំនូវបំណងប្រាថ្នាដែលពោរពេញទៅដោយ អំណោយទាននៃសេចក្ដីសប្បុរស ដែលជាសេចក្ដីស្រឡាញ់ដ៏សុទ្ធសាធនៃព្រះគ្រីស្ទ។ សូមប្រើធនធានទាំងអស់ដែលអ្នក មានដើម្បីធ្វើការល្អ ដើម្បីនាំមកនូវភាពធូរស្បើយ និងសេចក្ដីសង្គ្រោះដល់អស់អ្នក ដែលនៅជុំវិញអ្នក រួមទាំងក្រុមគ្រួសាររបស់អ្នកផ្ទាល់ផងដែរ។ ព្រះអម្ចាស់ នឹងប្រទានពរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់អ្នក ជាមួយនឹងភាពជោគជ័យ។

សូមឲ្យចំណេះដឹងរបស់យើង ចំពោះសេចក្ដីស្រឡាញ់ដ៏មហិមាដែលព្រះវរបិតា និងព្រះរាជបុត្រាមានចំពោះយើង ព្រមទាំងសេចក្ដីជំនឿ និងអំណរគុណរបស់យើងចំពោះ ដង្វាយធួន ដែលបំផុសយើងឲ្យអភិវឌ្ឍន៍ និងអនុវត្តន៍ សេចក្ដីសប្បុរសចំពោះអស់អ្នកដែនៅជុំវិញយើង។ នេះគឺជាការអធិស្ឋានរបស់ខ្ញុំ នៅក្នុងព្រះនាមនៃព្រះយេស៊ូវ គ្រីស្ទ អាម៉ែន។

កំណត់ចំណាំ

1. កូរិនថូសទី1 13:13។
2. កូរិនថូសទី1 13:4—8។
3. Joseph Smith ក្នុង *Daughters in My Kingdom: The History and Work of Relief Society* (2011), 23។
4. Joseph Smith នៅក្នុង *Daughters in My Kingdom,* 17។
5. សូមមើល មរ៉ូណៃ 7:47 ។
6. កូល៉ុស  3:14.
7. នីហ្វៃទី2  26:30 ។
8. សូមមើល មរ៉ូណៃ 7:48។
9. សូមមើល អេធើ 12:34 មរ៉ូណៃ 10:21។
10. សូមមើល គោលទ្ធិ និងសេចក្ដីសញ្ញា 88:125 ។
11. មរ៉ូណៃ 7:48។
12. យ៉ូហាន 21:16--17។
13. Thomas S. Monson « Charity Never Faileth » *Liahona* និង *Ensign* ខែ វិច្ឆិកា ឆ្នាំ 2010 ទំព័រ 124។
14. Henry B. Eyring « The Enduring Legacy of Relief Society » *Liahona* and *Ensign* ខែ វិច្ឆិកា ឆ្នាំ 2009 ទំព័រ 121។
15. Joseph Smith ក្នុង Relief Society Minute Book, Nauvoo, Illinois, ថ្ងៃទី 28 ខែ វិច្ឆិកា ឆ្នាំ 1982 ទំព័រ 38--39។